# សេចក្តីថ្លែងការណ៍រួម
# របស់អង្គការសង្គមស៊ីវិលដែលធ្វើការលើកស្ទួយសិទ្ធិស្ត្រីនៅកម្ពុជា
# ចំពោះករណី "កញ្ញា ខុម ចាន់តារាទី" ហៅ "ស្រីមុំ"

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៦

យើងខ្ញុំទាំងអស់ដែលជាសមាជិក សមាជិកានៃអង្គការសង្គមស៊ីវិលដែលធ្វើការលើកស្ទួយសិទ្ធិស្ត្រីនៅកម្ពុជាដែលមានឈ្មោះដូចខាងក្រោមមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបញ្ហាអំពើហិង្សាផ្អែកលើយេនឌ័រដែលចេះតែបន្តកើតឡើងមិនចេះឈប់ឈរ មានជាអាទិ៍នាពេលថ្មីៗនេះគឺករណី "កញ្ញា ខុម ចាន់តារាទី" ហៅ "ស្រីមុំ" ដែលបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម និងបណ្តាសារព័ត៌មានក្នុងស្រុកមួយចំនួនបានចុះផ្សាយនូវជីវិតឯកជនរបស់គាត់យ៉ាងគំហុក ហើយបច្ចុប្បន្នករណីរបស់គាត់ត្រូវបានតុលាការចេញដីកាកោះទាក់ទងនឹងការចោទប្រកាន់នូវបទល្មើសចំនួន ២ ផ្សេងគ្នាគឺករណីផ្តល់សក្ខីកម្មក្លែង និងមានអំពើពេស្យាចារនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៦ ។

យើងខ្ញុំសូមរក្សាសិទ្ធិមិនបកស្រាយចំពោះបញ្ហាខ្សែអាត់សម្លេងរវាងឯកឧត្តម កឹម សុខា និងកញ្ញាស្រីមុំ ថាពិតឬមិនពិតនោះទេ ។ ប៉ុន្តែយើងខ្ញុំមើលឃើញថា ៖

ទី១ ការដែលជ្រៀតជ្រែកដោយធ្វើការផ្សព្វផ្សាយអំពីជីវិតឯកជនរបស់កញ្ញាស្រីមុំ គឺជាការរំលោភសិទ្ធិមនុស្ស ដោយផ្អែកទៅលើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលជាអន្តរជាតិដែលក្នុងនាមរដ្ឋជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេសមាត្រា ១៧ នៃ កតិកាសញ្ញានេះដែលចែងថា "...គ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្តឬដោយខុស ច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយសនិងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ.." ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូល ជាពិសេស មាត្រា ៤០ ក៏បានចែងថា "...ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លង តាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមនាគមន៍ និងតាមទូរស័ព្ទត្រូវបានធានា..."។ ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទដែលតម្រូវឲ្យរដ្ឋភាគីត្រូវចាត់វិធានការទូទៅដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងគ្រប់រូបភាពទៅលើស្ត្រី និងធានាថាស្ត្រីទាំងអស់ទទួលបានសិទ្ធិតាមអនុសញ្ញា ច្បាប់សិទ្ធិមនុស្សផ្សេងៗទៀត ។

ទី២ ដីកាកោះហៅរបស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចំពោះកញ្ញា ខុម ចាន់តារាទី"ហៅ "ស្រីមុំ" ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៦ នូវបទល្មើសចំនួន ២ ផ្សេងគ្នាគឺករណីផ្តល់សក្ខីកម្មក្លែង និងអំពើពេស្យាចារគឺជាការចោទប្រកាន់ដោយគ្មានឈរលើមូលដ្ឋានច្បាស់លាស់។

ទី៣ អំពើនិងការចោទប្រកាន់ខាងលើនេះកំពុងតែធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់កិត្តិយស កេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់គាត់ ហើយស្ថានភាពនេះបានធ្វើឲ្យគាត់បាត់បង់ការងារ និងកំពុងរស់នៅ

ដោយភ័យខ្លាចនិងបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ដោយសារតែបុគ្គលដែលពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់ក្នុងករណីនេះគឺជាអ្នកនយោបាយនិងជាថ្នាក់ដឹកនាំនៃគណបក្សធំទាស់ ។

ផ្អែកលើហេតុផលខាងលើយើងខ្ញុំយល់ឃើញថាករណីនេះគឺជាការប្រើប្រាស់ស្ត្រីជាកម្មវត្ថុក្នុងការទាញយកផលប្រយោជន៍ផ្នែកនយោបាយរបស់គណបក្សនយោបាយ ។ ករណីកើតឡើងខាងលើបានកំពុងធ្វើឲ្យប្រជាពលរដ្ឋទូទៅដែលរស់នៅក្នុងប្រទេសកម្ពុជាមានអារម្មណ៍ភ័យខ្លាច អសុវត្ថិភាពទៅលើជីវិតឯកជនរបស់ពួកគាត់ (ការលួចថតសម្លេង) និងបាត់បង់ជំនឿកាន់តែខ្លាំងចំពោះប្រព័ន្ធតុលាការ ព្រមទាំងមានការបែកបាក់ក្នុងសង្គមផងដែរ ។

យើងទាំងអស់គ្នា សូមអំពាវនាវដល់ ៖

- រដ្ឋាភិបាលកម្ពុជាត្រូវធានាដល់ការគោរពនិងការពារសិទ្ធិស្ត្រីគឺសិទ្ធិមនុស្សផ្អែកលើការប្តេជ្ញាចិត្តរបស់ខ្លួន ដោយស្វែងរកមធ្យោបាយណាដែលមានប្រសិទ្ធិភាពដើម្បីបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពដែលរំលោភបំពាននិង គំរាមកំហែងលើសិទ្ធិបុគ្គល និងត្រូវធ្វើការផ្តន្ទាទោសដល់ជនណាដែលបានបរិហារកេរ្តិ៍ គំរាមកំហែង និង ចោទប្រកាន់គាត់ដោយគ្មានឈរលើមូលដ្ឋានច្បាស់លាស់ដើម្បីជាគំរូដល់ជនដទៃទៀត។
- ស្ថាប័នតុលាការដែលជាស្ថាប័នឯករាជ្យត្រូវប្រើតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមច្បាប់ប្រកបដោយតម្លាភាព និងយុត្តិធម៌ ។
- ជនដែលពាក់ព័ន្ធក្នុងករណីនេះត្រូវចូលរួមទទួលខុសត្រូវ និងបញ្ឈប់ជាបន្ទាន់នូវការយកស្ត្រីជាកម្មវត្ថុដើម្បីជាប្រយោជន៍នយោបាយ ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

១. លោកស្រី ធីតា ឃិះ នាយិកាអង្គការសីលការ ០១២ ៨៣៨ ៤៦៤ ។

២. លោកស្រី រស់ សុភាព នាយិកាអង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា(GADC) ០១២ ៦២៧ ៨៥៧។

៣. លោកស្រី ធន សុគន្ធា ប្រធានកម្មវិធីស្ត្រី នៃអង្គការអាដហុក (ADHOC) ០១២ ៣៤៤ ៧១៩។

**ក្រុមអង្គការសង្គមស៊ីវិលដែលយល់ព្រមគាំទ្រសេចក្តីថ្លែងការណ៍នេះមានរាយឈ្មោះដូចខាងក្រោម ៖**

១. អង្គការអាដហុក (ADHOC)

២. កម្មវិធីថ្នាក់តំបន់អាស៊ីអាគ្នេយ៍ (JASS SEA)

៣. អង្គការសីលការ (SILAKA)

៤. គណៈកម្មការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP)

៥. អង្គការខុមហ្វ្រែល (COMFREL)
៦. បណ្តាញពង្រឹងសិទ្ធិអំណាចស្ត្រីវ័យក្មេង (CYWEN)
៧. អង្គការស្ត្រីខ្មែរ (SK)
៨. អង្គការបន្ទាយស្រី (BS)
៩. អង្គការសមាគមធាងត្នោត (STT)
១០. អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍(BCV)
១១. មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC)
១២. សមាគមប្រជាធិបតេយ្យ ឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(IDEA)
១៣. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
១៤. មជ្ឈមណ្ឌសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
១៥. អង្គការសមធម៌កម្ពុជា (Equitable Cambodia)
១៦. អង្គការយុវជនខ្មែរ (KYA)
១៧. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
១៨. បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ (GADNet)
១៩. បណ្តាញបុរសកម្ពុជា (CMN)
២០. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)